# វគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាព ក្រុមប្រឹក្សាភិបាលសហគមន៍អភិវឌ្ឍន៍កសិកម្ម

នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១១ បណ្តាញកសិករនិងធម្មជាតិ បានរៀបចំនូវ វគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាព ដល់ក្រុមប្រឹក្សាភិបាលសហគមន៍អភិវឌ្ឍន៍កសិកម្មចំនួន ៤ មកពី ៤ខេត្តរួមមានខេត្តតាកែវ កំពត កំពង់ស្ពឺ និងកំពង់ឆ្នាំង នៅការិយាល័យអង្គការសេដាក ក្រុងភ្នំពេញ។ អ្នកចូលរួមចំនួន ៣១នាក់ (ស្ត្រី ៦នាក់) បានចូលរួម ដែលរួមមានប្រធាន អនុប្រធាន ក្រុមប្រឹក្សាភិបាល និងជំនួយការតាមខេត្តទាំងបួនផងដែរ។ វគ្គបណ្តុះបណ្តាលនេះសម្របសម្រួលដោយ លោកឆុង សុផល (អ្នកសម្របសម្រួលជំនួញសហគមន៍ស្រូវ) និងលោកបណ្ឌិតយ៉ង សាំងកុមារ ប្រធានអង្គការសេដាក ព្រមទាំងមានការចូលរួមពីលោកប៉ាន សុភាព (នាយកបណ្តាញកសិករនិងធម្មជាតិ) និងលោកអ៊ួន សុផល ប្រធាន បណ្តាញកសិករនិងធម្មជាតិ។ កិច្ចប្រជុំនេះទទួលបានការឧត្ថម្ភពីសមាគមសហករណ៍កាណាដា (CCA)។ វគ្គបណ្តុះបណ្តាលនេះ ធ្វើឡើងក្នុងគោលបំណងដូចខាងក្រោម:

- ចែករំលែកបទពិសោធន៍ជោគជ័យ របស់សហគមន៍អភិវឌ្ឍន៍កសិកម្ម រយៈពេល ៦ខែ ពី ខែមករា ដល់មិថុនា ឆ្នាំ២០១១
- ឆ្លុះបញ្ចាំងពីសហគមន៍នីមួយៗនៅតាមខេត្ត
- រៀបចំផែនការរយៈពេលពីរខែ របស់សហគមន៍